**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១៩៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការប្រគល់មុខងារគ្រប់គ្រង និងផ្តល់សេវាសុខាភិបាល ទៅឱ្យរដ្ឋបាលរាជធានី ខេត្ត

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

- បានឃើញព្រះរាជក្រឹត្យ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៧៣ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងមុខងារសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ចនិងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ចនិងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុងនិងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ៦៨ អនក្រ.បក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១២ ស្តីពីដំណើរការទូទៅនៃការផ្ទេរមុខងារ និងធនធានឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ០៦ អនក្រ.បក ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៧ ស្តីពីការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់ប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈនិងរដ្ឋមន្ត្រីក្រសួងសុខាភិបាល

**សម្រេច**

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលបំណងធ្វើឱ្យប្រសើរឡើងនូវការផ្តល់សេវាសុខាភិបាល ប្រកបដោយគុណភាព សុក្រឹតភាព ប្រសិទ្ធភាព និងសមធម៌នៅក្នុងព្រះរាជាណាចក្រកម្ពុជា តាមរយៈការបង្វិតការធ្វើសេចក្តីសម្រេចចិត្ត និងការទទួលខុសត្រូវក្នុងការគ្រប់គ្រងសេវាសុខាភិបាលឱ្យទៅកៀកជិតប្រជាពលរដ្ឋ។

**មាត្រា ២.-**

អនុក្រឹត្យនេះមានគោលដៅៈ

- ប្រគល់មុខងារគ្រប់គ្រងមន្ទីរសុខាភិបាល ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ និងការផ្តល់សេវាសុខាភិបាលនៃមន្ទីរពេទ្យបង្អែករាជធានី ខេត្ត មន្ទីរពេទ្យបង្អែកក្រុង ស្រុក ខណ្ឌ មណ្ឌលសុខភាព និងប៉ុស្តិ៍សុខភាពទៅឱ្យរដ្ឋបាលរាជធានី ខេត្ត
- ផ្ទេរធនធានហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និងធនធានមនុស្សឱ្យទៅរដ្ឋបាលរាជធានី ខេត្ត សម្រាប់អនុវត្តមុខងារសុខាភិបាលដែលបានប្រគល់ និង
- កំណត់ការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលរាជធានី ខេត្ត ដើម្បីគាំទ្រ និងអនុវត្តមុខងារសុខាភិបាលដែលបានប្រគល់។

**មាត្រា ៣.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តនៅគ្រប់រដ្ឋបាលរាជធានី ខេត្តទូទាំងប្រទេសក្នុងការអនុវត្តមុខងារសុខាភិបាលដែលបានប្រគល់ដូចមានកំណត់ក្នុងមាត្រា៤នៃអនុក្រឹត្យនេះ។

## ជំពូកទី២

## ការប្រគល់មុខងារសុខាភិបាលទៅឱ្យរដ្ឋបាលរាជធានី ខេត្ត

**មាត្រា ៤.-**

ប្រគល់មុខងារគ្រប់គ្រង និងផ្តល់សេវានៃមន្ទីរសុខាភិបាល ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិព្រមទាំងសេវាសំណុំសកម្មភាពបង្គ្រប់នៃមន្ទីរពេទ្យបង្អែករាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងសេវាសំណុំសកម្មភាពអប្បបរមានៃមណ្ឌលសុខភាព និងកញ្ចប់សេវាសុខភាពនៃប៉ុស្តិ៍សុខភាពទៅឱ្យរដ្ឋបាលរាជធានីខេត្ត។

រដ្ឋបាលរាជធានី ខេត្តត្រូវធ្វើប្រតិភូកម្មមុខងារគ្រប់គ្រង និងផ្តល់សេវាសុខាភិបាលជាក់លាក់មួយចំនួនទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយមាន

ការពិគ្រោះយោបល់ និងការឯកភាពជាមុនពីក្រសួងសុខាភិបាល ក្រោមការដឹកនាំ និងការសម្របសម្រួលរបស់ គ.ជ.អ.ប.។

**មាត្រា ៥.-**

គោលការណ៍ បែបបទ នីតិវិធី និងស្តង់ដាសម្រាប់អនុវត្តមុខងារពាក់ព័ន្ធនឹងការគ្រប់គ្រង និងផ្តល់សេវាសុខាភិបាលដែលបានប្រគល់ទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ត្រូវកំណត់ដោយក្រសួងសុខាភិបាល ដោយមានការពិគ្រោះយោបល់ជាមួយក្រសួងមហាផ្ទៃ និងក្រសួង ស្ថាប័នពាក់ព័ន្ធ។

## ជំពូកទី៣

## ការផ្ទេរធនធានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ

**មាត្រា ៦.-**

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.) ដឹកនាំ សម្របសម្រួលជាមួយក្រសួងសុខាភិបាល ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋបាលរាជធានី ខេត្ត ដើម្បីកំណត់អំពីទំហំធនធានហិរញ្ញវត្ថុ លក្ខខណ្ឌហិរញ្ញវត្ថុ លក្ខខណ្ឌបច្ចេកទេស និងលក្ខខណ្ឌផ្សេងៗទៀតដែលត្រូវផ្ទេរទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ដើម្បីគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់សម្រាប់អនុវត្តមុខងារសុខាភិបាលដែលបានប្រគល់។

លក្ខខណ្ឌហិរញ្ញវត្ថុ លក្ខខណ្ឌបច្ចេកទេស និងលក្ខខណ្ឌនានានៃការផ្ទេរហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌទៅឱ្យរដ្ឋបាលរាជធានី ខេត្តសម្រាប់អនុវត្តមុខងារសុខាភិបាលដែលបានប្រគល់ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងក្រសួងសុខាភិបាល ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ។

**មាត្រា ៧.-**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវរៀបចំ និងផ្ទេរធនធានហិរញ្ញវត្ថុទៅឱ្យរដ្ឋបាលរាជធានី ខេត្តសម្រាប់អនុវត្តមុខងារសុខាភិបាលដែលបានប្រគល់តាមនីតិវិធីជាធរមាន។

**មាត្រា ៨.-**

រដ្ឋបាលរាជធានី ខេត្តនីមួយៗត្រូវរៀបចំគម្រោងថវិកា និងអនុវត្តថវិកាប្រចាំឆ្នាំតាមគោលការណ៍ និងនីតិវិធីជាធរមាន ដើម្បីអនុវត្តមុខងារសុខាភិបាលដែលបានប្រគល់។

**មាត្រា ៩.-**

គ.ជ.អ.ប. ត្រូវដឹកនាំ សម្របសម្រួលជាមួយក្រសួងសុខាភិបាល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ ដើម្បីកំណត់អំពីទ្រព្យសម្បត្តិដែលត្រូវផ្ទេរទៅឱ្យរដ្ឋបាលរាជធានី ខេត្ត សម្រាប់ប្រើប្រាស់ក្នុងការអនុវត្តមុខងារសុខាភិបាលដែលបានប្រគល់។

ការផ្ទេរទ្រព្យសម្បត្តិនេះត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយមានការដឹកនាំសម្របសម្រួលពី គ.ជ.អ.ប.។

**មាត្រា ១០.-**

រដ្ឋបាលរាជធានី ខេត្តអាចប្រើប្រាស់ធនធានគ្មានភ្ជាប់លក្ខខណ្ឌ និងធនធានដែលគៀរគរបានពីប្រភពស្របច្បាប់ផ្សេងទៀត ព្រមទាំងទ្រព្យសម្បត្តិផ្ទាល់របស់រដ្ឋបាលរាជធានី ខេត្ត សម្រាប់គាំទ្របន្ថែមដល់ការអនុវត្តមុខងារសុខាភិបាលដែលបានប្រគល់។

**មាត្រា ១១.-**

រដ្ឋបាលរាជធានី ខេត្តត្រូវគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ធនធានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិដែលបានទទួលសម្រាប់អនុវត្តមុខងារសុខាភិបាលដែលបានប្រគល់ស្របតាមលក្ខខណ្ឌ និងនីតិវិធីជាធរមាន។

## ជំពូកទី៤

## ការផ្ទេរធនធានមនុស្ស

**មាត្រា ១២.-**

គ.ជ.អ.ប. ត្រូវដឹកនាំ សម្របសម្រួលជាមួយក្រសួងសុខាភិបាល ក្រសួងមុខងារសាធារណៈ រដ្ឋបាលរាជធានី ខេត្ត និងអង្គភាពពាក់ព័ន្ធនានា ដើម្បីកំណត់អំពីប្រភេទ និងចំនួនបុគ្គលិកសុខាភិបាលដែលកំពុងបម្រើការនៅមន្ទីរសុខាភិបាលរាជធានី ខេត្ត និងមន្ទីរពេទ្យបង្អែករាជធានី ខេត្ត ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ មន្ទីរពេទ្យបង្អែកក្រុង ស្រុក ខណ្ឌ មណ្ឌលសុខភាព និងប៉ុស្តិ៍សុខភាព ដើម្បីផ្ទេរទៅឱ្យរដ្ឋបាលរាជធានី ខេត្តសាមីនីមួយៗ។

**មាត្រា ១៣.-**

ក្រសួងសុខាភិបាលត្រូវសហការជាមួយក្រសួងមុខងារសាធារណៈ ដើម្បីរៀបចំលិខិតបទដ្ឋានផ្ទេរបុគ្គលិកសុខាភិបាលដែលបានកំណត់ដូចមានចែងក្នុងមាត្រា១២នៃអនុក្រឹត្យនេះទៅឱ្យរដ្ឋបាលរាជធានី ខេត្តស្របតាមគោលការណ៍ បែបបទ និងនីតិវិធីដែលបានកំណត់ដោយព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។

បុគ្គលិកសុខាភិបាលដែលបានផ្ទេរទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ត្រូវបានធានានូវមុខតំណែង លក្ខខណ្ឌការងារ ប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗទៀតមិនទាបជាងលក្ខខណ្ឌការងារ ប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងទៀតដែលបុគ្គលិកទាំងនោះធ្លាប់បានទទួលមុនពេលផ្ទេរ។

**មាត្រា ១៤.-**

ការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់បុគ្គលិកដែលបានផ្ទេរទៅឱ្យរដ្ឋបាលរាជធានី ខេត្តត្រូវអនុលោមតាមព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។

## ជំពូកទី៥

## រចនាសម្ព័ន្ធ តួនាទី ភារកិច្ច និងគណនេយ្យភាពរបស់រដ្ឋបាលរាជធានី ខេត្ត

## ផ្នែកទី១

## រចនាសម្ព័ន្ធ តួនាទី ភារកិច្ច

**មាត្រា ១៥.-**

ត្រូវបានបង្កើតមន្ទីរសុខាភិបាលចំណុះឱ្យរដ្ឋបាលរាជធានី ខេត្ត តាមរយៈការធ្វើសមាហរណកម្ម រចនាសម្ព័ន្ធគ្រប់គ្រងបច្ចុប្បន្ននៃមន្ទីរសុខាភិបាលនៃក្រសួងសុខាភិបាល។

មន្ទីរពេទ្យបង្អែករាជធានី ខេត្ត ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ មន្ទីរពេទ្យបង្អែកក្រុង ស្រុក ខណ្ឌ មណ្ឌលសុខភាព និងប៉ុស្តិ៍សុខភាពត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់មន្ទីរសុខាភិបាល នៃរដ្ឋបាលរាជធានី ខេត្ត។

មុខតំណែងនានានៃរចនាសម្ព័ន្ធគ្រប់គ្រងបច្ចុប្បន្នរបស់មន្ទីរសុខាភិបាលនៃក្រសួងសុខាភិបាល មន្ទីរពេទ្យបង្អែករាជធានី ខេត្ត ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ មន្ទីរពេទ្យបង្អែកក្រុង ស្រុក ខណ្ឌ មណ្ឌលសុខភាព និងប៉ុស្តិ៍សុខភាពដែលត្រូវបានធ្វើសមាហរណកម្មមកក្រោមការគ្រប់គ្រងរបស់រដ្ឋបាល រាជធានី ខេត្តត្រូវរក្សាកម្រិត និងឋានៈដដែល។

មន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានី ខេត្តត្រូវបំពេញតួនាទីជាសេនាធិការឱ្យក្រុមប្រឹក្សា និង គណៈអភិបាលរាជធានី ខេត្តលើការអនុវត្តមុខងារដែលបានប្រគល់ដូចបានកំណត់ក្នុងមាត្រា៤នៃ អនុក្រឹត្យនេះ។

**មាត្រា ១៦.-**

ការរៀបចំ និងការប្រព្រឹត្តទៅនៃមន្ទីរសុខាភិបាលរបស់រដ្ឋបាលរាជធានី ខេត្តត្រូវកំណត់ដោយ ប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសុខាភិបាល និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដោយមានការពិគ្រោះ យោបល់ជាមួយក្រសួងមុខងារសាធារណៈ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រោមការដឹកនាំសម្រប សម្រួលពី គ.ជ.អ.ប.។

**មាត្រា ១៧.-**

រដ្ឋបាលរាជធានី ខេត្តត្រូវទទួលខុសត្រូវលើការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារ សុខាភិបាលដែលបានប្រគល់ឱ្យមានប្រសិទ្ធភាពស្របតាមគោលនយោបាយសុខាភិបាលជាតិ ផែនការ យុទ្ធសាស្ត្រ មគ្គុទ្ទេសក៍ណែនាំស្តីពីការប្រតិបត្តិគ្លីនិក ពិធីសារនៃការពិនិត្យព្យាបាល ស្តង់ដាគុណភាព និងបទដ្ឋានបច្ចេកទេសនានា។

ដើម្បីអនុវត្តមុខងារសុខាភិបាលទាំងនេះ រដ្ឋបាលរាជធានី ខេត្តត្រូវៈ

- រៀបចំផែនការសកម្មភាពប្រចាំឆ្នាំសម្រាប់អនុវត្តមុខងារសុខាភិបាលដែលបានប្រគល់
- ផ្អែកលើផែនការសកម្មភាពប្រចាំឆ្នាំ ត្រូវរៀបចំគម្រោងថវិកាសម្រាប់អនុវត្តមុខងារសុខាភិបាល ដែលបានប្រគល់ស្របតាមលក្ខខណ្ឌនានា និងតាមនីតិវិធីហិរញ្ញវត្ថុ ដូចមានកំណត់ក្នុង មាត្រា៦ និងមាត្រា៧នៃអនុក្រឹត្យនេះ

- គ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ធនធានហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និងបុគ្គលិកដែលបានផ្ទេរសម្រាប់អនុវត្តមុខងារសុខាភិបាលដែលបានប្រគល់ឱ្យមានប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព ស្របតាមគោលការណ៍ បែបបទ នីតិវិធី និងបទដ្ឋានបច្ចេកទេសដែលបានកំណត់
- លើកសំណើជូនក្រសួងសុខាភិបាលអំពីតម្រូវការមន្ត្រីវិជ្ជាជីវៈសុខាភិបាល និងតម្រូវការនៃការបណ្តុះបណ្តាលមន្ត្រីវិជ្ជាជីវៈសុខាភិបាលដែលកំពុងបម្រើការក្នុងមន្ទីរសុខាភិបាល មន្ទីរពេទ្យបង្អែករាជធានី ខេត្ត ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ មន្ទីរពេទ្យបង្អែកក្រុង ស្រុក ខណ្ឌ មណ្ឌលសុខភាព និងប៉ុស្តិ៍សុខភាព
- អនុវត្តមុខងារក្នុងនាមជាភ្នាក់ងារក្នុងការអនុវត្តកម្មវិធីជាតិសុខាភិបាលនានា
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនានាដើម្បីគាំទ្រដល់ការអនុវត្តមុខងារសុខាភិបាលដែលបានប្រគល់
- កៀរគរការគាំទ្រថវិកា សម្ភារ និងបច្ចេកទេសពីអ្នកពាក់ព័ន្ធនានា និងអាចប្រើប្រាស់ធនធានឆន្ទានុសិទ្ធិរបស់រដ្ឋបាលរាជធានី ខេត្ត ដើម្បីបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាសុខាភិបាលក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- រៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តមុខងារសុខាភិបាលដែលបានប្រគល់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួនមកក្រសួងសុខាភិបាល និងក្រសួងមហាផ្ទៃ ព្រមទាំងធ្វើរបាយការណ៍ហិរញ្ញវត្ថុតាមគោលការណ៍ និងនីតិវិធីកំណត់។

## ផ្នែកទី២

## គណនេយ្យភាព

**មាត្រា ១៨.-**

រដ្ឋមន្ត្រីក្រសួងសុខាភិបាលទទួលខុសត្រូវ និងមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល និងរដ្ឋសភាលើវិស័យសុខាភិបាល។

ក្រុមប្រឹក្សា និងគណៈអភិបាលរដ្ឋបាលរាជធានី ខេត្តត្រូវមានគណនេយ្យភាព និងការទទួលខុសត្រូវចំពោះរដ្ឋមន្ត្រីក្រសួងសុខាភិបាលក្នុងការគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារសុខាភិបាលដែលបានប្រគល់ឱ្យស្របតាមគោលនយោបាយសុខាភិបាលជាតិ ផែនការយុទ្ធសាស្ត្រសុខាភិបាលជាតិ មគ្គុទ្ទេសក៍ណែនាំស្តីពីការប្រតិបត្តិគ្លីនិក ពិធីសារនៃការពិនិត្យព្យាបាល ស្តង់ដាគុណភាព និងបទដ្ឋានបច្ចេកទេសនានាដែលបានកំណត់ និងត្រូវមានគណនេយ្យភាពចំពោះប្រជាជនក្នុងការផ្តល់សេវាសុខាភិបាលក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ប្រធានមន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានី ខេត្តត្រូវមានគណនេយ្យភាព និងការទទួលខុសត្រូវចំពោះក្រុមប្រឹក្សា និងគណៈអភិបាលនៃរដ្ឋបាលរាជធានី ខេត្ត ក្នុងការគ្រប់គ្រង ការគាំទ្រផ្នែកបច្ចេកទេស និងតាមដានត្រួតពិនិត្យលើការផ្តល់សេវារបស់មន្ទីរពេទ្យបង្អែករាជធានី ខេត្ត ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ មន្ទីរពេទ្យបង្អែកក្រុង ស្រុក ខណ្ឌ មណ្ឌលសុខភាព និងប៉ុស្តិ៍សុខភាពក្នុង

ដែនសមត្ថកិច្ចរបស់រដ្ឋបាលរាជធានី ខេត្តសាមីនីមួយៗ។

ប្រធានមន្ទីរពេទ្យបង្អែករាជធានី ខេត្ត និងប្រធានការិយាល័យសុខាភិបាលស្រុកប្រតិបត្តិត្រូវមានគណនេយ្យភាព និងការទទួលខុសត្រូវចំពោះប្រធានមន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានី ខេត្ត។

ប្រធានមន្ទីរពេទ្យបង្អែកក្រុង ស្រុក ខណ្ឌ ប្រធានមណ្ឌលសុខភាព និងប្រធានប៉ុស្តិ៍សុខភាពត្រូវមានគណនេយ្យភាព និងការទទួលខុសត្រូវចំពោះប្រធានការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ។

## ជំពូកទី៦

## យន្តការគាំទ្រ ការតាមដាន ត្រួតពិនិត្យ និងការវាយតម្លៃ

**មាត្រា ១៩ .-**

គ.ជ.អ.ប. ដឹកនាំ សម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាដល់ការប្រគល់មុខងារសុខាភិបាល និងធនធានទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ព្រមទាំងសម្របសម្រួលផ្តល់ការគាំទ្រដល់រដ្ឋបាលរាជធានី ខេត្តក្នុងការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព ស្របតាមគោលនយោបាយសុខាភិបាលជាតិ ផែនការយុទ្ធសាស្ត្រសុខាភិបាលជាតិ មគ្គុទ្ទេសក៍ណែនាំស្តីពីការប្រតិបត្តិគ្លីនិក ពិធីសារនៃការពិនិត្យព្យាបាល ស្តង់ដាគុណភាព និងបទដ្ឋានបច្ចេកទេសនានា។

**មាត្រា ២០.-**

ក្រសួងសុខាភិបាលមានតួនាទី ភារកិច្ចដូចខាងក្រោម៖

- រៀបចំគោលនយោបាយសុខាភិបាលជាតិ និងផែនការយុទ្ធសាស្ត្រសុខាភិបាលជាតិ មគ្គុទ្ទេសក៍ ណែនាំស្តីពីការប្រតិបត្តិគ្លីនិក ពិធីសារនៃការពិនិត្យព្យាបាល ស្តង់ដាគុណភាព និងបទដ្ឋានបច្ចេកទេសនានា
- រៀបចំច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំដើម្បីបង្កើនគុណភាពសេវាសុខភាពសាធារណៈ និងឯកជន
- រៀបចំ និងគ្រប់គ្រងការអនុវត្តកម្មវិធីជាតិការពារជំងឺគ្រប់ប្រភេទ កម្មវិធីបង្ការ និងការថែទាំវេជ្ជសាស្ត្រ ដើម្បីបន្ថយមូលហេតុនៃជំងឺ និងផ្តល់ការគាំទ្រដល់ការផ្តល់សេវាបង្ការ ពិនិត្យព្យាបាល និងថែទាំ
- សិក្សាស្រាវជ្រាវ ដើម្បីអភិវឌ្ឍវិស័យសុខាភិបាល
- កសាងផែនការអភិវឌ្ឍន៍ធនធានមនុស្សវិស័យសុខាភិបាល ជ្រើសរើស និងបែងចែកគ្រូពេទ្យបុគ្គលិកជំនាញសុខាភិបាល
- កំណត់និយាម ចំនួន និងមុខតំណែងវិជ្ជាជីវៈរបស់បុគ្គលិកសម្រាប់មន្ទីរពេទ្យបង្អែក មណ្ឌលសុខភាព និងប៉ុស្តិ៍សុខភាព
- រៀបចំកម្មវិធី និងអភិវឌ្ឍសមត្ថភាពអំពីការគ្រប់គ្រង ការចាត់ចែងមុខងារដែលបានប្រគល់

ដល់រដ្ឋបាលរាជធានី ខេត្ត ដើម្បីលើកកម្ពស់ប្រសិទ្ធភាព គុណភាព និងសមធម៌ក្នុងការផ្តល់សេវាថែទាំសុខភាព

- បណ្តុះបណ្តាលមូលដ្ឋាន និងបណ្តុះបណ្តាលបន្តដល់អ្នកប្រកបវិជ្ជាជីវៈសុខាភិបាល
- កំណត់លក្ខណៈវិនិច្ឆ័យ នីតិវិធី គោលការណ៍ណែនាំ និងស្តង់ដាអប្បបរមាសម្រាប់ការបង្កើតនិងដំណើរការមន្ទីរពេទ្យបង្អែក មណ្ឌលសុខភាព ប៉ុស្តិ៍សុខភាព មន្ទីរពហុព្យាបាល គ្លីនីកឯកជន បន្ទប់ពិនិត្យ និងពិគ្រោះជំងឺ
- កំណត់និយាមសម្រាប់ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធសុខាភិបាល និងប្លង់គំរូសាងសង់នៃការសាងសង់មន្ទីរពេទ្យ មណ្ឌលសុខភាព និងការសម្រេចបង្កើតមន្ទីរពេទ្យ និងមណ្ឌលសុខភាពគ្រប់ប្រភេទ
- កំណត់បញ្ជីស្តង់ដាឱសថសារវ័ន្ត បរិក្ខារពេទ្យ ឧបករណ៍អមវេជ្ជសាស្ត្រសម្រាប់មន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព
- រៀបចំកិច្ចលទ្ធកម្ម និងបែងចែកឱសថសារវ័ន្ត បរិក្ខាពេទ្យ ឧបករណ៍អមវេជ្ជសាស្ត្រដល់រដ្ឋបាលរាជធានី ខេត្ត តាមគោលការណ៍កំណត់
- កៀរគរធនធានសម្រាប់អភិវឌ្ឍវិស័យសុខាភិបាល
- ផ្តល់ការគាំទ្របច្ចេកទេសក្នុងការកសាងផែនការប្រតិបត្តិ និងផែនការថវិកាដោយរាប់បញ្ចូលទាំងអន្តរាគមន៍សុខភាពសាធារណៈនៃកម្មវិធីសុខភាពនានាដល់រដ្ឋបាលរាជធានី ខេត្ត
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការគ្រប់គ្រង និងការផ្តល់សេវាសុខាភិបាលដែលអនុវត្តដោយរដ្ឋបាលរាជធានី ខេត្ត។

**មាត្រា ២១.-**

ក្រសួងមហាផ្ទៃមានតួនាទីសម្របសម្រួល សហការ គាំទ្រ និងតាមដានត្រួតពិនិត្យ វាយតម្លៃលើការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារដែលបានប្រគល់ដូចមានកំណត់ក្នុងមាត្រា៤នៃអនុក្រឹត្យនេះ។

**មាត្រា ២២.-**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានតួនាទីគាំទ្រ និងតាមដាន ត្រួតពិនិត្យលើការចាត់ចែង និងការប្រើប្រាស់ធនធានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិដែលបានផ្ទេរទៅឱ្យរដ្ឋបាលរាជធានី ខេត្ត សម្រាប់អនុវត្តមុខងារដែលបានប្រគល់។

**មាត្រា ២៣.-**

ក្រសួងមុខងារសាធារណៈមានតួនាទីគាំទ្រដល់ការផ្ទេរបុគ្គលិកសុខាភិបាល និងតាមដានត្រួតពិនិត្យលើការគ្រប់គ្រង និងការចាត់ចែងបុគ្គលិកដែលបានផ្ទេរទៅឱ្យរដ្ឋបាលរាជធានី ខេត្ត។

## ជំពូកទី៧

## ក្របខ័ណ្ឌពេលវេលានៃការអនុវត្ត

**មាត្រា ២៤.-**

គ.ជ.អ.ប. ត្រូវដឹកនាំ សម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីរៀបចំលិខិតបទដ្ឋាននានាដែលពាក់ព័ន្ធនឹងការផ្ទេរបចនាសម្ព័ន្ធ បុគ្គលិក ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ ព្រមទាំងផ្សព្វផ្សាយខ្លឹមសារនៃអនុក្រឹត្យនេះឱ្យបានចប់សព្វគ្រប់មុនដំណាច់ឆ្នាំ២០១៩។

**មាត្រា ២៥.-**

រដ្ឋបាលរាជធានី ខេត្តត្រូវចាប់ផ្តើមគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារដែលបានប្រគល់ដូចមានកំណត់ក្នុងមាត្រា៤នៃអនុក្រឹត្យនេះចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២០តទៅ។

ក្រោមការដឹកនាំ និងការសម្របសម្រួលរបស់គ.ជ.អ.ប. រដ្ឋបាលរាជធានី ខេត្តត្រូវធ្វើការសិក្សា និងកំណត់មុខងារសមស្របមួយចំនួនពាក់ព័ន្ធនឹងការគ្រប់គ្រង និងការផ្តល់សេវាសុខាភិបាល ដើម្បីធ្វើប្រតិភូកម្មទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់ចាប់ពីឆ្នាំ២០២០តទៅ។

## ជំពូកទី៨

## អវសានប្បញ្ញត្តិ

**មាត្រា ២៦.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ២៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ក្រុមប្រឹក្សានិងគណៈអភិបាលរាជធានី ខេត្ត ក្រុមប្រឹក្សា និងគណៈអភិបាលក្រុង ស្រុក ខណ្ឌ និងក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ៣..៨កើត ខែកត្តិក.. ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី....៤....ខែ....១១......ឆ្នាំ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមមេត្តាចុះហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**និងជាប្រធាន គ.ជ.អ.ប.**

**សម្តេចក្រឡាហោម ស ខេង**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**

**កិត្តិបណ្ឌិត ពេជ្រ ប៊ុនធិន**

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

**ម៉ម ប៊ុនហេង**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ